## រឿងទី៨៖ កូនចៀមវង្វេងមួយក្បាល

**ខគម្ពីរ៖ លូកា១៥៖៧**

ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់នៅស្ថានបរមសុខមានអំណរសប្បាយ ដោយមានមនុស្សបាបតែម្នាក់កែប្រែចិត្តគំនិត ខ្លាំងជាងព្រះអង្គសប្បាយនឹងមនុស្សសុចរិតកៅសិបប្រាំបួននាក់ ដែលមិនត្រូវការកែប្រែចិត្តគំនិត។

បណ្តាជនចង់ស្តាប់ព្រះបន្ទូលព្រះយេស៊ូ។ ដូច្នេះ បណ្តាជនប្រមូលផ្តុំគ្នាយ៉ាងច្រើន គ្រប់ទីកន្លែងដែលព្រះយេស៊ូយាងទៅ។
ប៉ុន្តែ មានមនុស្សខ្លះមិនចូលចិត្តព្រះយេស៊ូទេ។ ដូច្នេះ ព្រះយេស៊ូបាននិទានរឿងមួយទៅកាន់ពួកគេ។
កាលពីព្រេងនាយ មានអ្នកគង្វាលមានចៀមចំនួនមួយរយក្បាល។ អ្នកគង្វាលនោះស្រឡាញ់ចៀមរបស់គាត់ណាស់។
ពេលដល់វេលាត្រឡប់ទៅផ្ទះវិញ អ្នកគង្វាលបានរាប់ចំនួនចៀមនៅឯវាល។ ប៉ុន្តែ ទោះបីជារាប់យ៉ាងណា ឃើញចៀមមានចំនួនតែកៅសិបប្រាំបួនក្បាលប៉ុណ្ណោះ។ អ្នកគង្វាលបារម្ភពីចៀមមួយដែលបាត់នោះណាស់។ គាត់ចាប់ផ្តើមដើររកវាគ្រប់ទីកន្លែង។
ពេលវេលាយប់កាន់តែយប់ជ្រៅ។ អ្នកគង្វាលនោះបានដើររកចៀម ធ្លាក់ទឹកផង ដួលផង។
ប៉ុន្តែគាត់មិនបោះបង់ឡើយ គាត់នៅតែបន្តដើររកចៀមដដែល។ នៅគ្រានោះ ស្រាប់តែគាត់បានឮសំឡេងអ្វីមួយ! អ្នកគង្វាលបានរត់ទៅកន្លែងដែលឮសំឡេងនោះ! ចៀមដែលបានបាត់កំពុងជាប់នៅលើកំពូលទីទួលមួយ។ ចៀមដ៏កំសត់ សើម ហើយញ័រដោយភាពភ័យខ្លាច។
អ្នកគង្វាលបានជួយសង្គ្រោះចៀម។ គាត់រីករាយណាស់ ហើយបានដាក់ចៀមពីលើស្មា រួចត្រឡប់ទៅផ្ទះវិញ។
ពេលអ្នកគង្វាលទៅដល់ផ្ទះវិញ គាត់បានស្រែកដោយក្តីសោមនស្សរីករាយទៅកាន់ប្រពន្ធ និងកូនៗថា៖
«ខ្ញុំបានរកឃើញហើយ! ខ្ញុំបានរកឃើញចៀមដែលបាត់ហើយ! គាត់ក៏ហៅគ្នីគ្នាមក ដើម្បីធ្វើពិធីជប់លៀង!»
ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់បណ្តាជនថា៖
«តើនៅពេលដែលអ្នករាល់គ្នាបានរកឃើញចៀមដែលបានបាត់ អ្នកមិនរីករាយទេឬ? ព្រះជាម្ចាស់នៅស្ថានបរមសុខមានអំណរសប្បាយដោយមានមនុស្សបាបតែម្នាក់កែប្រែចិត្តគំនិត ខ្លាំងជាងព្រះអង្គសប្បាយនឹងមនុស្សសុចរិតកៅសិបប្រាំបួននាក់ដែលមិនត្រូវការកែប្រែចិត្តគំនិត។ ព្រះជាម្ចាស់មិនសព្វព្រះទ័យឱ្យបាត់បង់នរណាម្នាក់ឡើយ»។ ព្រះអង្គក៏បាននិយាយអំពីរឿងមួយផ្សេងទៀតពីអ្នកគង្វាល និងសត្វចៀមដែរ។ អ្នកគង្វាលល្អតែងតែងស្គាល់ចៀមរបស់ខ្លួន។ ចៀមក៏ស្គាល់សំឡេងម្ចាស់ ហើយដើរតាម។
ប៉ុន្តែ ចៀមរត់គេចនៅពេលដែលឮសំឡេងមនុស្សប្លែកមុខ។ នៅពេលដែលមានសត្វកាចសាហាវមកយាយីសត្វចៀម អ្នកគង្វាលល្អនឹងប្រយុទ្ធជាមួយវា។ អ្នកគង្វាលល្អតែងតែការពារចៀមរបស់ខ្លួន។
ព្រះយេស៊ូមានព្រះបន្ទូលថាទ្រង់អាចឱ្យបានសូម្បីតែជីវិត ដើម្បីការពារចៀមរបស់ទ្រង់។







**សកម្មភាពទី១** ស្វែងរកចម្លើយដោយប្តូរនិមិត្តសញ្ញាទៅជាតួអក្សរ។




a. តើអ្នកគង្វាលមានចៀមប៉ុន្មានក្បាល? € – ◁ ..................................

b. ក្នុងចំណោមចៀមមួយរយ តើមានរឿងអ្វីកើតឡើងចំពោះចៀមមួយ? ♧ – ▩ – ↓ ..........................................

c. សូមអានលូកា១៥:៧ រួចឆ្លើយសំណួរ។ ព្រះជាម្ចាស់នៅស្ថានបរមសុខមានអំណរសប្បាយ ដោយមានមនុស្សបាបតែម្នាក់ ធ្វើអ្វី?

ⓚ – ★ – ≠ – ☞ – ☎ ..........................

**សកម្មភាពទី២** កាត់ធ្វើជារូបរាងចៀម រួចបោះរន្ធនៅក្នុងវា។ បន្ទាប់មក យកសំឡីទៅបិទនឹងចៀមដើម្បីធ្វើតុក្កតាម្រាមដៃ។



- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (លូកា១៥:៧)

**ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់នៅស្ថានបរមសុខមានអំណរសប្បាយ ដោយមានមនុស្សបាបតែម្នាក់កែប្រែចិត្តគំនិត ខ្លាំងជាងព្រះអង្គសប្បាយនឹងមនុស្សសុចរិតកៅសិបប្រាំបួននាក់ ដែលមិនត្រូវការកែប្រែចិត្តគំនិត»។**